

EAST-WEST SEED FOUNDATION

KNOWLEDGE TRANSFER

# វិចទ័រសត្វល្អិត៣សំខាន់ៗ ចម្លងជំងឺវីរុសរុក្ខជាតិ ការណែនាំអំពីបច្ចេកទេស



## • តើហេតុអ្វីចាំបាច់ត្រូវស្គាល់វិចទ័រសត្វល្អិត ?



## • តើអ្វីជាវិចទ័រសត្វល្អិត៣សំខាន់ៗចម្លងជំងឺវីរុសរុក្ខជាតិ?

វិចទ័រសត្វល្អិត = សត្វល្អិតដែលអាចនាំយកជំងឺវីរុសពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត។

វីរុសរុក្ខជាតិ = មីក្រូសរីរាង្គដែលបណ្តាលអោយមានការចម្លងមេរោគដល់រុក្ខជាតិ ។

ពពួកចៃជញ្ជក់រុក្ខរស



រុយស



ទ្រីប



## • រោគសញ្ញាទូទៅនៃការបំផ្លាញ



រួញស្វិតដោយសារការ
បឺតជញ្ជក់យករុក្ខរសរុក្ខជាតិ។



កើតមានផ្សិតម្រែងភ្លើងដោយសារ
តែការបញ្ចេញចោលទឹកដម
ពីពពួកចៃជញ្ជក់រុក្ខរស និងរុយស។



ស្លាកស្នាមពណ៌ប្រាក់នៅលើស្លឹក
ដោយសារការបំផ្លាញពីទ្រីប ។

## • តើវិចទ័រសត្វល្អិតបញ្ជូនមេរោគវីរុសបានយ៉ាងដូចម្តេច?




ចំណាំ: រុក្ខជាតិខ្ចី (ដំណាក់កាលសំណាប) គឺងាយនឹងឆ្លងមេរោគជាងរុក្ខជាតិចាស់។

## • រោគសញ្ញាទូទៅនៃជំងឺវីរុស


គ្រិន


រួញ


លឿង


ម៉ូសាអ៊ិច


ស្នាមប្រតេកប្រតាក


តូចរៀវ

## • ជំងឺវីរុសសំខាន់ៗភាគច្រើនត្រូវបានចម្លងដោយវិចទ័រសត្វល្អិត

### ពពួកចៃជញ្ជក់រុក្ខរស


ជំងឺវីរុសលឿងបង្កដោយចៃជញ្ជក់រុក្ខរសលើអំបូរត្រសក់ ( CABYV )


ជំងឺវីរុសអុជរង្វង់ល្ហុង ( PRSV )


ជំងឺវីរុសលឿងម៉ូសាអ៊ិចននោងបារាំង ( ZYMV )


ជំងឺវីរុសស្នាមទ្រនុងស្លឹកម្ទេស ( ChiVMV )


ជំងឺវីរុសម៉ូសាអ៊ិចត្រសក់ ( CMV )

### រុយស


ជំងឺវីរុសរួញស្លឹកម្ទេស ( PepLCV )


ជំងឺវីរុសរួញស្លឹកប៉េងប៉ោះ ( TLCV )


ជំងឺវីរុសរួញស្លឹកល្ពៅក្តាម ( SLCV )


ជំងឺវីរុសរួញស្លឹកពោតបារាំង ( OELCuV )


ជំងឺវីរុសម៉ូសាអ៊ិចលឿងទ្រនុងស្លឹកពោតបារាំង ( OYVMV )

### ទ្រីប


ជំងឺវីរុសស្លោកអុជៗប៉េងប៉ោះ (TSWV)


ជំងឺវីរុសស្នាមប្រាក់ឪឡឹក ( WMSMoV )


ជំងឺវីរុសអុជលឿង ( MYSV )

ពិនិត្យមើលរោគសញ្ញាច្រើន មិនអាចប្រើរោគសញ្ញាតែមួយមុខដើម្បីកំណត់រោគវិនិច្ឆ័យជំងឺវីរុសច្បាស់លាស់នោះទេ ខណៈដែលរោគសញ្ញាមួយអាចបណ្តាលមកពីវីរុសខុសៗគ្នាជាច្រើន។

សួរអ្នកឯកទេសក្នុងតំបន់ ប្រសិនបើមានការសង្ស័យ។

# • តើត្រូវគ្រប់គ្រងរុិចទ័រសត្វល្អិត និងវីរុសដែលចម្លងមកតាមរបៀបណា ?

## ការបង្ការ: តើត្រូវប្រុងប្រយ័ត្នតាមរបៀបណា ?


ពិនិត្យមើលប្រវត្តិនៃការដាំដំណាំ ច្បារដំណាំ និងកត្តាសត្វល្អិតចង្រៃ។


ការដាំដំណាំបង្វិល



ប្រើប្រាស់ពូជដែលធន់ទ្រាំនឹងជំងឺវីរុស


ប្រើរោងបណ្ដុះដែលមានសំណាញ់ហ៊ុំជុំវិញដើម្បីការពារកូនដំណាំ


ការប្រើកៅស៊ូគ្របរង


ត្រូវដាំរុក្ខជាតិផ្កា ដើម្បីទាក់ទាញសត្វល្អិតមានអត្ថប្រយោជន៍


ត្រូវសម្អាតស្មៅ ឬស្មូន ដើម្បីជៀសផុតពីជម្រកជំងឺ

## ការត្រួតពិនិត្យ៖ តើត្រូវពិនិត្យវត្តមានរុិចទ័រសត្វល្អិតតាមរបៀបណា ?


ត្រូវពិនិត្យជាប្រចាំថ្ងៃនៅក្នុងច្បារដំណាំ


ត្រូវរកមើលនៅផ្នែកខាងក្រោមស្លឹក


ត្រូវពិនិត្យស្លឹកដែលខូច ឬរួញ ផ្សិតម្រែងភ្លើង និងស្លាកស្នាមពណ៌ប្រាក់



ត្រូវប្រើអន្ទាក់ស្អិតពណ៌លឿង (ពពួករុយស និងពពួកចៃជញ្ជក់រុក្ខរស) និងពណ៌ខៀវ (ពពួកទ្រីប)

## ការអន្តរាគមន៍៖ តើត្រូវធ្វើអ្វីខ្លះនៅពេលមានវត្តមានរុិចទ័រសត្វល្អិត ?


ត្រូវដករុក្ខជាតិដែលមានជំងឺចេញ និងបំផ្លាញចោល (ដុតចោល)

| ធាតុសកម្ម | ក្រុមបែបផែនធាតុសកម្ម | ពពួកចៃជញ្ជក់រុក្ខរស | ពពួករុយស | ពពួកទ្រីប |
|---|---|---|---|---|
| ថ្នាំចំរាញ់ពីស្តៅ | មិនស្គាល់ | ✔ | ✔ | ✔ |
| អាសេតាមីព្រីដ (Acetamiprid) | 4A | ✔ | ✔ | ✔ |
| ស្ពីនូសាដ (Spinosad) | 5 | ✔ | ✔ | ✔ |
| អុីម៉ាមេទីន បង់សូអាត (Emamectin benzoate) | 9B | ✔ | ✔ | ✔ |

* មិនត្រូវបាញ់ថ្នាំក្នុងអំឡុងពេលចេញផ្កា

- ត្រូវប្រើឆ្លាស់ក្រុមបែបផែនធាតុសកម្ម ដើម្បីបង្ការការកើនឡើងនូវភាពស៊ាំថ្នាំកសិកម្ម
- ត្រូវធានានូវការបាញ់ថ្នាំកសិកម្មបានសព្វល្អនៅផ្នែកក្រោមស្លឹក
- ត្រូវប្រើឧបករណ៍ការពារខ្លួន (PPE) នៅពេលកំពុងបាញ់ថ្នាំកសិកម្ម
- ត្រូវលាងសម្អាតបន្ទាប់ពីបាញ់ថ្នាំរួច

**http://growhow.eastwestseed.com**
*This technical guide is part of a series produced by EWSF. @2021 Copyright of East-West Seed Foundation. All Rights Reserved*
*Agrochemical recommendations have been developed in cooperation with Wageningen University & Research*

WAGENINGEN
UNIVERSITY & RESEARCH